# អនុក្រឹត្យលេខ ៣៦ អនក្រ

## ស្ដីពី មុខងារនិងភារកិច្ច របស់ទីប្រឹក្សាក្រសួងការពារជាតិ នៃរាជរដ្ឋាភិបាល ព្រះរាជាណាចក្រកម្ពុជា

*រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៤*

- បានឃើញ រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះបាទសម្ដេច ព្រះនរោត្តម សីហនុវរ្ម័ន្ទ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្ដីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**សំរេច**

ប្រការ ១ : ទីប្រឹក្សាក្រសួងការពារជាតិ មានភារកិច្ចដូចតទៅ :

ក- ជួយរដ្ឋមន្ត្រី ក្នុងវិស័យនយោបាយការពាជាតិ ជាពិសេសក្នុងការរៀបចំរចនាសម្ព័ន្ធការគ្រប់គ្រងការធ្វើឲ្យមានប្រសិទ្ធិភាពក្នុងកិច្ចបំរើការងារ និងកំណែទកងកំលាំងទាំងអស់ការផ្ដល់ហេដ្ឋារចនាសម្ព័ន្ធយោធាជាចាំបាច់ និងការរៀបចំអនុវត្តន៍ក្នុងវិស័យការពារផ្ទៃប្រទេស ។

ខ- សិក្សា និងស្នើមតិទៅរដ្ឋមន្ត្រី ដើម្បីធ្វើការណែនាំដល់គ្រប់នាយកដ្ឋានក្តី ភូមិភាគយោធាក្តី តំបន់សឹករងអង្គភាពក្តីក្នុងសកម្មភាពផលិតកម្មកិច្ចការពារប្រមូលផ្តុំ និងប្រើប្រាស់ធនធានគ្រប់ប្រភេទ ដើម្បីជាប្រយោជន៍ក្នុងកិច្ចការការពារជាតិ ។

គ-ធ្វើសេចក្តីរាយការណ៍ជូនរដ្ឋមន្ត្រី នូវការវិវឌ្ឍន៍រាល់បញ្ហាដែលទាក់ទង និងការការពារជាតិក្នុងវិស័យនយោបាយក៏ដូចជាវិស័យបច្ចេកទេស ។

ប្រការ២ : ទីប្រឹក្សាត្រូវមានលេខាធិការដ្ឋានរួមមួយ ដើម្បីជាជំនួយការងារដោយមានបុគ្គលិកមួយចំនួនដែលមានក្របខ័ណ្ឌក្នុងក្រសួងស្រាប់ ។

ប្រការ ៣ : មានសិទ្ធិក្នុងការទាក់ទងគ្រប់នាយកដ្ឋាន អគ្គសេនាធិការយោធភូមិភាគ តំបន់ប្រតិបត្តិការសឹករង អង្គភាពកងអាកាសចរណ៍ខេមរភូមិន្ទ និង កងនាវាចរណ៍ខេមរភូមិន្ទ ក្រសួងមហាផ្ទៃនិងសន្តិសុខ ដើម្បីប្រមូលនូវពត៌មានណាដែលសំខាន់ក្នុងកិច្ចការការពារជាតិ ។

ប្រការ ៤ : ទីប្រឹក្សានឹងត្រូវបានទទួលភារកិច្ចបន្ថែមតាមការសំរេចរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

ប្រការ ៥ : សហរដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងសន្តិសុខ នាយអគ្គសេនាធិការនៃកងយោធពលខេមរភូមិន្ទ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី២ |
|---|---|
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| នរោត្តម រណឫទ្ធិ | ហ៊ុន សែន |

* * *

**អនុក្រឹត្យលេខ ៣៧ អនក្រ**

**ស្តីពីការបែងចែកសិទ្ធិចុះហត្ថលេខាលើ**

**អត្តសញ្ញាណប័ណ្ណ នាយទាហាន នាយទាហានរង**

**និង ពលទាហាន ខ្ជូជាំង កងយោធពលខេមរភូមិន្ទ**

*ភ្នំពេញថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៤*

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញក្រឹត្យចុះថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ១៩៩៣ ស្តីពីការចាត់តាំងបង្កើតក្រសួងការពារជាតិ និង អគ្គសេនាធិការដ្ឋាន